ឧបសៅសង្ហា

# សណ្ឋាន និង គោលការណ៍

LA POSTURE ET LE PRINCIPE



សណ្ឋាន (La posture)

## មាតិការឿង


អារម្ភកថា........................................................................................2

សណ្ឋាន នយោបាយ នៅ ស្រុកខ្មែរ ................................................5

គោលការណ៍ នយោបាយ នៅ ស្រុកខ្មែរ.........................................9

សេចក្តីសន្និដ្ឋាន .............................................................................15

# សណ្ឋាន និង គោលការណ៍

## អារម្ភកថា

នៅក្នុង ជីវិតភាព នយោបាយ[1] ការប្រុងប្រយ័ត្ន របស់ អ្នកនយោបាយ គឺ ជៀសវៀង កុំ ឲគោលការណ៍ នយោបាយ ក្លាយជា សណ្ឋាន នយោបាយ ព្រោះ ជា ការប្រែផ្លាស់ពី ចលនារើក ទៅជា ចលនា មិនកម្រើកៗ មានកាលខ្លះ សណ្ឋាន វា ធ្វើអោយក្រិន នូវ ការ ត្រិះរិះរៀស (pensée active) ដែល វា ផ្ទុយពី ធម្មជាតិ របស់ មនុស្ស ជា សត្វលោក ដែលចេះគិតពិចារណាៗ មានពេលខ្លះ គោលការណ៍ មាន សទិសភាព នឹង មច្ឆាចិន្តា (mal pensant) ព្រោះគ្រឿងផ្សំ គំនិត វា មិនសមតាមនឹង ចំណោទ នៃ បញ្ហាៗ តែ គោល ទាំងពីរនេះ ក៏ វាមាន តម្លៃ សជ្ឈន្តិកៈ[2] និងមានមុខងារជា ប្រយោជន៍ រៀងៗខ្លួនៗ សណ្ឋាន វា អាចជា របង ការពារ ឧត្តមគតិ ដូចគ្នានឹង គោលការណ៍ វា អាចជា ឫទ្ធិអា ថកំប្បាំង(mystique) ការពារ តម្លៃ នៃ សកម្មភាត, មានកាលខ្លះ វាសស្រាំ ទៅវិញទៅមក ដូចចិត្តនឹងកាយ នៅក្នុង មនោសាស្ត្រ (esprit) នៃ ការការពារ ប្រយោជន៍ ទូទៅៗ នៅក្នុង ជីវិតភាពនយោបាយ វា ទាំងពីរ មាន ភាពចង្រ្កងចម្រាស់ ព្រោះវា អាស្រ័យទៅលើ គោល គំនិត នៃ អ្នកនយោបាយ ដែល ច្រើន ជា អ្នក មាន ឫទ្ធិអាថកំប្បាំង ដ្បិតនយោបាយ វា ជា ឫទ្ធិអាថកំប្បាំងរួចស្រេចទៅហើយៗ ជាទូទៅ អ្វីជាជំនឿច្រើន ជា ឫទ្ធិអាថកំប្បាំង ព្រោះ ជា មមង្គារ (propriété en soi) ឬ ជា លក្ខណសម្បត្តិ របស់រូបធាតុ (propriété) របស់ ខ្លួនផ្ទាល់ៗ សំនួរ សួរថា តើ សណ្ឋាន នយោបាយ និង គោលការណ៍ នយោបាយ ជា ជំនឿ ឬ ជា អំពើ នៅក្នុង នយោបាយ ? ចម្លើយ គឺថា វា មាន អាការ ទាំងពីយ៉ាងនេះ, បើ ជា អំពើ គឺជា សកម្មភាព ដែល គេ អាចមើលឃើញ នឹង ភ្នែក, បើជា ជំនឿ គេ អាចយល់ ដឹង ព្រោះវា ជា ប្រភព នៃ អំពើ ដែលកំពុងធ្វើ ដូចយ៉ាង អំពើល្អ អាច កើតមានបាន លុះ

---

1 ជីវិតភាព នយោបាយ= La vie politique។

2 សជ្ឈន្តិកៈ=ដែលមាននៅក្នុងខ្លួន ; intrinsèque។

គ្រា អ្នកធ្វើ មាន ចិត្ត ជឿលើ ជំនឿល្អ ដូច្នេះ ជនផ្ដាច់ការ មិនអាច ជា អ្នកដឹកនាំ មាន សេចក្ដីសប្បុរសទាន បាននោះឡើយ, ជន បែបនេះ បើធ្វើទាន គឺ ធ្វើ ដើម្បី ប្រោយ យកប្រយោជន៍ ផ្ទាល់ខ្លួន តែប៉ុណ្ណោះ។

សណ្ឋាន នយោបាយ វា អាច មាន ចរិកលក្ខណ: ជា ទិដ្ឋិ (dogme) ដូច ជា ទិដ្ឋិសាសនា ដែលមិនអាច កែច្នៃបាន នោះឡើយ ព្រោះ វាអាច វិសាយ សារជាតិ របស់ខ្លួន ដែល ជាតម្លៃ សជ្ឈន្តិក: ដូច គេ ច្នៃ ក្រូចឆ្មា អោយបាត់ ជាតិជូរ នោះឯង ដែល នាំ ឲបាត់ ជាតិធម្មជាតិ របស់វា។ តែ អ្នកខ្លះ យល់ថា ទិដ្ឋិ ជា ទ្រឹស្ដី បង្កើតឡើង ដោយមនុស្ស ដូច្នេះ អ្វី ជា មនុស្ស គឺ អនិច្ចំ, អ្វីជា ធម្មជាតិ គឺ អនិច្ចំ។ ការគ្មាន ថេរនៅនិត្យនេះឯង ដែល អាច ធ្វើអនុមាន បានថា ម្លេះ នរណា យល់ឃើញ ថា ទិដ្ឋីសាសនាក្ដី សណ្ឋាននយោបាយក្ដី ជា គំនិត ឥតអាច កែប្រែបាន ជា ការយល់ច្រឡំ, ទោះបី ព្រះពុទ្ធ ក៏ ព្រះអង្គ គ្រងទុកថា សិក្ខាបទរបស់ព្រះអង្គ មាន កំរិតពេលវេលា ត្រឹមតែ ប្រាំពាន់ឆ្នាំ តែប៉ុណ្ណោះ ព្រោះ ព្រះអង្គ ផ្អែងទៅលើ ទស្សន: នៃ អនិច្ចំ នូវ អ្វី គ្រប់យ៉ាង មាន នៅក្នុង លោកនេះ។ ដូចគ្នានឹង អវសាន នៃ របប កុម្មុយនិស្ដ នៅ ប្រទេស រុស្ស៊ី និង អឺរុបខាងកើតបញ្ជាក់ នូវអនិច្ចំ នៃ សណ្ឋាននយោបាយ នោះដែរ។ បើខ្មែរយើង យក ប្រាសាទ អង្គរវត្ត មកពិចារណា លើ សណ្ឋាន នៃ លទ្ធិនយោបាយ នៅ ជំនាន់នោះ តើ នរណា អាចជឿបាន ថា ឫទ្ធានុភាព នៃ មហានគរខ្មែរ អាច រលាយបាន រហូត បាត់សូន្យ ពី ស្មារតីខ្មែរ អស់ច្រើនសតវត្ស។

សណ្ឋាននយោបាយ នៅក្នុង ចលនា ថាមវ័ន្ត គឺ ជា អំពើ នៃ ការការពារ ដូចជា ខ្សែបន្ទាត់ ការពារ កងទ័ព ដែល មាន ចលនា នៅ ចំពោះ ការវាយប្រហារ របស់ខ្មាំងសត្រូវ ដើម្បី តម្រូវខ្លួនតាម ស្ថានភាព នៃ សមរភូមិ ដូច្នេះ សណ្ឋាន បែបនេះហើយ ជាអំពើ ព្រោះ វាជា កំពែងចលតផង ជា កម្លាំង នៃ ការវាយប្រហារផង ដូចជា កងឯកនាពរថគ្រោះនៅក្នុង

សមរត្ថមិ៍ៗ សណ្ឋាននយោបាយ ចលត គឺជា រន្ទា (échafaudage) សំរាប់បង្កើន គោលការណ៍ នយោបាយៗ

គោលការណ៍ ជា មនោគមវិជ្ជា សំរាប់ ចលនានយោបាយ ឬ ចក្ខុវិស័យ ដែលអាចធ្វើបាន ព្រោះ អំពើ នយោបាយ គឺ ចាំបាច់ ត្រូវធ្វើ ឲ្យបានសម្រេច នូវ អ្វី ដែល អ្នកនយោបាយសន្យា ថា នឹងធ្វើ, ដូច្នេះ គោលការណ៍នយោបាយ មិនមែនជា ទស្សនវិជ្ជា សំរាប់ពិចារណារក ហេតុផល ដើម្បី បញ្ញា សុទ្ធសាត នោះឡើយ តែ វាជា សកម្មភាព យក ឧត្តមគតិ មាននៅក្នុងគំនិត មកអនុវត្ត នៅក្នុងសង្គមៗ អ្វីដែលជា មនោគមវិជ្ជា គឺជាកិច្ចការ មធ្យ៉ូតណាស់ ព្រោះ វា ត្រូវមាន ក្រមសីលធមិ (règle éthique) របស់ វាផ្ទាល់ នៅក្នុង គោលសីលធម៌ នៃ សង្គម ដូច្នេះហើយ  បានជា នៅក្នុង នាយកធម៌ បូរាណ របស់ អ្នកដឹងនាំខ្មែរមានកំណត់ ជា កាតព្វកិច្ច ៦ យ៉ាង៖ ខមា (សេចក្តីអត់ធន់) ជាគរិយ: (សេចក្តីទ្មាក់រលើករឿយៗ) ខុដ្ឋាន (សេចក្តីខ្វស្សាហ៍ខ្នះខ្នែង) សិរិតាគ (ការចែករលែកឬការរំលែកឲ្នូវវត្ថុផ្សេងៗ) ទយា (សេចក្តីអាណិតអាសូរត្រាប្រណីគេ) ឥក្ខណា (ការរំពៃមើលខុសត្រូវ)ៗ អាស្រ័យហេតុនេះ បានជាគេ ទុក គោលការណ៍នយោបាយ ជា សារជាតិ នៃ អង្គការនយោបាយ ដែលមាន អ្នកដឹងនាំ និងសមាជិកម្នាក់ៗ មាន សីលធម៌ និង មាន កាតព្វកិច្ចៗ គណបក្ស នយោបាយ មិន អាច ជាទី សង្ឃឹម បើ ខ្លួនគ្មាន គោលការណ៍ នយោបាយច្បាស់លាស់ ហើយ មាន អ្នកដឹកនាំ គ្មាន សីលធម៌ នូវ មិនស្គាល់ កាតព្វកិច្ច របស់ខ្លួន ជាប្រមុខ (leader)ៗ គ្រាន់ តែបានធ្វើ កិច្ចការ បំរើជាតិ ទោះបី ច្រើនយ៉ាងណា ក៏ដោយ មិនមែន ជា លិខិតអនុញ្ញាត អោយ មេដឹកនាំ ប្រព្រឹត្ត អំពើ អសីលធម៌ និង បំពានច្បាប់ នោះបានឡើយៗ មេដឹងនាំ ល្អ គឺ ជា បុគ្គល ឥតខ្ចោះ ព្រោះ ខ្លួន មិនអាច មានដាច់ខាត នូវ អ្វីដែល ជា មន្ទិលសង្ស័យ លើ រូបខ្លួន និង មាន មន្ទភាព (naïveté) ដ្បិត ខ្លួន ជា អ្នកនាំផ្លូវ

ផង និង ជា គំរូផងៗ ទ្វេលក្ខណ: នេះឯង ជា បុគ្គល ឯកឧត្តម សំរាប់ អ្នកទាំងពួង ទុកអ្នកដឹកនាំ ជា បូជនីយបុគ្គលៗ

---

## សណ្ឋាន នយោបាយ នៅ ស្រុកខ្មែរ

---

នៅស្រុកខ្មែរ មាន សណ្ឋាន នយោបាយ ច្រើន ដូចយ៉ាង ៖

បក្ខព័ន្ធ[3]នៃរាជា (royaliste), បក្ខព័ន្ធនៃសីហានុ (Sihanoukiste), បក្ខព័ន្ធនៃហុនសែន (Hunseniste), បក្ខព័ន្ធនៃគណបក្ស (Partiste) ។លៗ បើនិយាយ ជា ពាក្យ សាមញ្ញ វិញ គេ ថាជា ជំនឿ ផ្គាប់មុខ ទៅលើបុគ្គល ឬ វត្ថុអ្វីមួយៗ ជំនឿផ្គាប់មុខ នេះ វាឃាត់ មិនឲមាន បច្ចវេក្ខណ: (ការពិចារណា) រកការពិត នៅក្នុងគំនិត ហើយ ក៏ជា ប្បាតប័ត្រ[4] នៅចំពោះមុខបញ្ហា ដែលមាន ជំនឿ ជឿថា ត្រូវតែមាន មេដឹកនាំ ជា អតិសិត្តជន (homme sacré) ទើបអាច ដោះស្រាយបាន, ជំនឿបែបនេះ វាដូចជា ការគោរពអតិសិត្តជន[5] ដែលច្រើនមាន នៅក្នុង សង្គម ហួសសម័យ ឬ របបសក្តិភូមិៗ បក្ខព័ន្ធ… (…iste) នេះឯង ជា សណ្ឋាននោយបាយ អវិជ្ជមាន ដែល យើងលើក ឧទាហរណ៍មួយ មក រំលឹក សំរាប់យកមក ពិចារណា: មេដឹកនាំ គណបក្សប្រឆាំង នៅពេល ធ្វើ មីទិង ម្តងៗ គេ អង្គុយលើកៅអី កិត្តិយស ដូច បល្ល័ង្ក ទំលើ វេទិកា ដូច ស្តេច ឬ ធ្វើ ឫកដូច នរិន្ទ[6] នៅមុខ ប្រជាជនធិបតេយ្យៗ កង្វះនាពជា ជនសាមញ្ញ នេះឯង ជា សណ្ឋាន អវិជ្ជមាន ជាក់ស្តែងមួយៗ កៅអី កិត្តិយស គេ ប្រើនៅក្នុង ពិធី ជា ផ្លូវការ ដែល ជា ពិធី របស់រដ្ឋ សំរាប់ អោយកិត្តិយស ដល់ មុខងារ ជាផ្លូវការ ដល់ អ្នកតំណាង នៃ នីតិរដ្ឋៗ នៅក្នុង ប្រទេស ប្រជាធិ

---

3 បក្ខព័ន្ធ= អ្នកដែលមានចិត្តស្មគ្រចំពោះមនុស្ស ឬ កិច្ចការណាមួយ។
4 ប្បាតប័ត្រ= ការលះបង់សិទ្ធិអោយអ្នកណាម្នាក់ ; Résignation។
5 ការគោរអតិសិត្តជន= culte de personnalité។
6 នរិន្ទ= អ្នកដែលជាធំលើអស់ជន, ដែលជាម្ចាស់នៃមនុស្ស។

បតេយ្យ នៅពេល ប្រជុំ គណបក្ស គេមិនដែលមាន កៅអី កិត្តិយស លយចេញដាច់ ដូច បល្ល័ងស្តេចនោះឡើយ, របៀបបែបនេះ មាន តែ នៅក្នុង ចលនាកុម្មុយនិស្តៗ នៅស្រុកខ្មែរ អ្នកនយោបាយ គាត់នៅមានចរិក ទុកគាត់ ជា ម្ចាស់នៃ ប្រជារាស្ត្រ, ចរិកដុះស្លែនេះហើយ ដែល ជា ពន្លឺឆ្លុះ (reflet) មកលើ រាល់ទង្វើ របស់គាត់ ឥតដឹងខ្លួន នៅចំពោះមុខ ប្រជាពលរដ្ឋ នោះឯង ដែល គេ ហៅថា វប្បធម៌ អ្នកធំៗ

សណ្ឋាន អវិជ្ជមាន មួយ នៃ អ្នកដឹកនាំ គណបក្សនយោបាយ គឺ បក្ខព័ន្ធនៃការបោះឆ្នោត (électionistes) ទុក គណបក្ស ជា បក្ស គិត តែ ពីការបោះឆ្នោត ម្តងហើយម្តងទៀត (R-électioniste) គ្មាន ពេលវេលា ហើយ ឥតប្រកបដោយល័ក្ខខ័ណ្ឌៗ ខ្ទឹហាត (obstination) នេះ គឺជា សញ្ញា បង្ហាញថា អ្នកដឹកនាំបក្ស មិនមែនជា អ្នកប្រជាធិបតេយ្យនិយមនោះទេ តែផ្ទុយទៅវិញ ពួកគាត់ ជា បក្ខព័ន្ធនៃប្រជាធិបតេយ្យ (démocratisme) មាន គំនិតច្រឡំ ថា ការបោះឆ្នោត ជាដំណោះស្រាយ គ្រប់ បញ្ហានយោបាយ និង សង្គម នៅស្រុកខ្មែរ; តែការពិត នីតិវិធី នៃ ការបោះឆ្នោត គ្រាន់តែជា ការប្រកួតកម្លាំងនយោបាយ[7] តាមសន្តិវិធី តែប៉ុណ្ណោះ ដូច្នេះ ត្រូវមាន ជា បឋម ច្បាប់បោះឆ្នោត ត្រឹមត្រូវ, អង្គការ រៀបចំបោះឆ្នោតឯករាជ្យ ហើយនឹង អង្គការយុត្តិធម៌កំពូល ប្រកបដោយ ឧបេក្ខា (impartialité) សំរាប់ វិនិច្ឆ័យ នូវ ភាពមិនប្រក្រតី នៃ ការបោះឆ្នោតៗ ដោយយោង ទៅលើ រាល់ ការបោះឆ្នោត កន្លងមក យើងឃើញថា ល័ក្ខខ័ណ្ឌ ដែលបានរៀបរាប់ខាងលើ មិនគ្រប់គ្រាន់ ដែលមិនអាច ទុក ការបោះឆ្នោត នៅស្រុកខ្មែរ ជា ការបោះឆ្នោតត្រឹមត្រូវ ស្របតាម គំនិត ប្រជាធិបតី បាននោះឡើយៗ ហេតុនេះហើយ ក្នុង ការប្រកួតកម្លាំងនយោបាយ ជា បឋម ត្រូវស្វែងរក គ្រប់ ល័ក្ខខ័ណ្ឌ ដែលអាច អោយមាន ការបោះឆ្នោតត្រឹមត្រូវ មិនមែន ចាំ បោះឆ្នោតរួច សុំនាំគ្នា គិត បន្តទៅទៀត ព្រោះ គិត បែបនេះ វា ហួស ពេលវេលា បាត់ទៅ

[7] ការប្រកួតកម្លាំង នយោបាយ : Rapport de force politique។

ហើយ ; រួចកុំនាំគ្នាសង្ឃឹម ថាមាន បរទេស ជា មហាអំណាចក្តី ជា សហគមអន្តរជាតិក្តី គេនឹងមកជួយ ដោះស្រាយបញ្ហាខ្មែរ អោយខ្មែរ។ បោះឆ្នោតបែបនេះ ជា ការប្រឆាំងនឹងប្រជាធិបតី តែប៉ុណ្ណោះ។

សណ្ឋានអវិជ្ជមាន របស់ អ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ គឺ មាននៅក្នុង ពាក្យស្លោក «មិនឆ្លើយនិងមិនឈ្លោះ» ប្រើនៅក្នុងគំនិត ជា បក្ខព័ន្ធនៃសន្តិភាព (pacifiste)។ តាមពិត គឺ ជា គំនិត យក «ភ័យ មកធ្វើជា វិន័យ» សំរាប់ សន្សំសុខ ឬ ជា ការរួមគំនិតក្នុង អំពើ ទុច្ចរិត ព្រោះ ជា ការបើក សិទ្ធិ ជា តុណ្ហី (tacite) អោយ គណបក្សកាន់អំណាចបំពានច្បាប់ គ្រប់បែបយ៉ាង ព្រោះ តុណ្ហីភាព (នៅស្ងៀម) ឬ គ្មានប្រតិកម្ម នៅក្នុង ជីវិតភាពនយោបាយ គេទុកជា ការរួមគំនិត។ ដូច្នេះ បក្ខព័ន្ធនៃសន្តិភាព គឺ ជា កំភរ កុហក ពីរជាន់ដល់ប្រជាពលរដ្ឋខ្មែរ គឺ កុហក ខ្មែរគ្នាឯងផង និង អ្នកក្រផង ដែលកំពុង រស់នៅ ក្នុង មហាទុក្ខគ្រប់បែបយ៉ាង។ និន្នាការ នយោបាយ នៃ បក្ខព័ន្ធនៃសន្តិភាព សព្វថ្ងៃ គឺ ពួកគាត់ នាំគ្នាដើរ ពន្យល់ រាស្ត្រ កុំអោយ ធ្វើសកម្មភាពនយោបាយ ហើយគិតតែ រៀបចំ មូលដ្ឋាន ដើម្បីចាំ បោះឆ្នោត ជានិរន្ត ហាក់បី ដូច ជា ទុក ប្រជាជនខ្មែរ ជា កូនក្មេង ត្រូវបញ្ជូលរឹលត្រឡប់ទៅ ក្នុង សិក្ខមានកាល (noviciat) ដើម្បី ឲស្គាល់ សិទ្ធិ និង ករណីកិច្ចជា ពលរដ្ឋ (citoyen) តែភ្លេចគិតថា ប្រជាពលរដ្ឋ ធ្លាប់បោះឆ្នោត ៥ អាណត្តិ រួចមកហើយ។ និន្នាការនេះ គឺ គ្រាន់តែជា ការបញ្ជាក់បន្ថែម នូវ ការ យក ភ័យខ្លាច ធ្វើជា វិន័យ របស់ បក្ខព័ន្ធសន្តិភាព នោះឯង។ សកម្មភាព បែបនេះ មាននៅតែ ក្នុង របប ផ្តាច់ការ អនុវត្ត **ពិធីប្រជាធិបតេយ្យ** (démocrature)[8] គឺថា យក លទ្ធិប្រជាធិបតេយ្យ មក បញ្ឆោត ប្រជាពលរដ្ឋ ជាពិធី ខូឡារិក ជា ពិសេស ការបោះឆ្នោត តែ ជា ការក្លែងក្លាយ ឬ បង្គ្រប់កិច្ចតែប៉ុណ្ណោះ។

[8] ពិធីប្រជាធិបតេយ្យ= Démocrature ជាទ្រឹស្តីនយោបាយថ្មី ដែលពួកអ្នកផ្តាច់យកមនអនុវត្តដោយប្រើលទ្ធិប្រជាធិបតេយ្យ គ្មានសារជាតិប្រជាធិបតេយ្យ។

សណ្ឋាន អវិជ្ជមាន មួយទៀត គឺ បក្ខព័ន្ធនៃហ៊ុនសែន ដែល ជា អ្នក បំរើ ប្រយោជន៍ យៀកណាម ព្រោះ ជា ជនខ្មែរទាំងនោះ ឬានទទួល កម្រៃ និង បុណ្យស័ក្ត ពី យៀកណាម ដ្បិត ស្រុកខ្មែរ ស្ថិត នៅក្រោម ការត្រួតត្រា នៃ មន្ត្រីយួន ក្លែងខ្លួនជា មន្ត្រីខ្មែរៗ ពួក នេះ នាំគ្នាបំផ្លាញធនធាន ធម្មជាតិខ្មែរ និង ប្រព្រឹត្តិ អំពើ ពុករលួយ រហូតជាតិរលាយ, បែង ចែក ទឹកដីខ្មែរ ជាសម្បត្តិ ឯកជន, តែងតាំងកូនចៅខ្លួន ជា ឧត្តមសេនីយ ឬ ឯកឧត្តម ធ្វើ ជា ជនអាន់ជ្រី ឬ មេក្លោង ពួកជនទុច្ចរិត នៅក្នុង ក្រសួង និង ក្នុង កងទ័ពជាតិៗ សណ្ឋាន បក្ខព័ន្ធហ៊ុនសែន ជា សេចក្តីស្រឡាញ់ ក្លែងក្លាយ ព្រោះ ជា អ្នក រេតាមខ្យល់ ថ្ងៃនេះ ធ្វើជា ស្រឡាញ់ ហ៊ុន សែន ព្រោះ យៀកណាម គេ ការពារ ហ៊ុន សែន តែ ថ្ងៃស្អែក អាចនឹងដូរ ចិត្ត ស្រឡាញ់ តួឯងថ្មី ដែល យៀកណាម គេ ជ្រើសរើស ឲដើរតួថ្មីៗ បើនិយាយ ជា សង្ខេប គឺថា បក្ខព័ន្ធហ៊ុនសែន គឺ គ្មានអ្វីក្រៅពី ស្រមោល នៃ បក្ខព័ន្ធនៃយួន នោះឯងៗ នៅ ស្រុកខ្មែរសព្វថ្ងៃ ដំណើរ នៃ យួនូបនីយកម្ម នៃសង្គមខ្មែរ មកដល់ដំណាក់ការ ចុង ក្រោយបង្អស់ ដែលមិនអាចវិលត្រឡប់ថយក្រោយវិញឬាន នោះឡើយៗ តើជា កម្មវាសនា គេចមិនរួច (fatum) របស់ ជនជាតិខ្មែរ ?

ចម្លើយ វា អាស្រ័យ នៅលើ ជីវកម្លាំង (force vive) នៃ ប្រជាពលរដ្ឋខ្មែរ, ហ៊ាន រាន ទីនឹង អំណាចយួន នៅស្រុកខ្មែរ ; បើ ខ្មែរ ខ្លាច គឺ ជាតិ ស្លាប់, បើ ខ្មែរ ក្លាហាន ជា អ្នក ការពារជាតិ គឺ ជាតិ រស់ៗ សព្វថ្ងៃ ខ្មែរ ចាញ់ កម្លាំងឬាយយួន ព្រោះ អ្នកដឹកនាំ និង អ្នក នយោឬាយខ្មែរ ជា មនុស្សល្ងង់ ហើយ ចោលម្សៀតៗ ដូច្នេះ នៅក្នុង ជីវកម្លាំង គឺ ខ្មែរ មិន ត្រូវ ចាញ់ចិត្ត, មិនព្រមចុះញ៉ម, ចងជាកម្លាំងជាតិ ដែលជា កម្លាំងតស៊ូ រំដោះជាតិ ក្នុងនាម ជា ពលរដ្ឋ អ្នកស្នេហាជាតិៗ បក្ខព័ន្ធនៃហ៊ុនសែន គ្មានគ្រិះ នយោឬាយ នោះឡើយ, វា ឈរឬាន ដោយសារ ប្រើ កម្លាំងទេរវកម្មរដ្ឋ គឺថា ប្រើអំណាចរដ្ឋ សំរាប់ ជិះជាន់ប្រជា ពលរដ្ឋ តែប៉ុណ្ណោះៗ លោក ហ៊ុន សែន គាត់និយាយថា គាត់ធ្វើ នាយករដ្ឋមន្ត្រីរហូត គាត់

ខ្ជីលធ្វើ ; យើងក៏យល់ឃើញដូចគាត់ដែរ ថា គាត់ ធ្វើ នាយករដ្ឋមន្ត្រី រហូតដល់ថ្ងៃស្លាប់ បើ គាត់ ធ្វើ ជា អ្នកបំរើ ប្រយោជន៍យួន នៅស្រុកខ្មែរៗ តើអ្វីទៅជា មោទនភាព របស់គាត់ជា កូនខ្មែរ ?

សណ្ឋាន នៃ បក្ខព័ន្ធនៃរាជា មានកំរិត នៅតែ ក្នុង រាជវង្សានុវង្ស ទ្រុឌទ្រោម ដែល យៀកណាមកុម្មុយនិស្ត គេ យកមក ទឹម ជាមួយនឹង បក្ខព័ន្ធហ៊ុនសែន ដើម្បីអូស រទេះ យួនកុម្មុយនិស្ត នៅ កម្ពុជាៗ សណ្ឋាន នេះ គឺ ជា ដង្ហើម ចុងក្រោយបង្អស់ នៃរាជានិយម ឬាក់ស្លាប ដែល កំពុង ទុំ លើ មែកឈើ ចិន/យួន កុម្មុយនិស្ត, មាន ស្តេច, ព្រះអង្គ រស់ ជា ទីងមោង ; ម្តេចក៏ដូច្នេះណ៎ា ? កុំថាឡើយ តែ រាស្ត្រ ក្ររហាម សព្វអន្លើ ក្នុងនគរ ស្ទូម្បីជាតិ ជិតស្លាប់ ក៏ ព្រះអង្គ ឥត រញ៉េរា ចុះហត្ថលេខា បន្ថែម ក្នុង ឆ្នាំ ២០០៥ ប្រគល់ ទឹកដីមួយចំណែកអោយ យៀកណាមៗ រាជកិច្ច នេះ នឹងទុក ស្នាមរាំក្នុងប្រវត្តិសាស្ត្រជាតិខេមរា ចងជាស្មារតី ថ្មី ថា ស្តេច លក់ ទឹកដី, ក្បត់សំដីខ្លួន ចារក្នុង សំបថ ក្នុងនាម ជា ព្រះ រាជពន្ទុមន្ត[9] នៃ ក្រុងកម្ពុជាធិបតេយ្យ មាន ព្រាហ្មណ៍បណ្ឌិត ជា សាក្សី មានទេវតា រក្សា ព្រះនគរ ញញឹមសរសើរ ហើយ អញ្ជើញ ព្រះពិរុណ មក ប្រោះ ទឹកមន្ត ថ្វាយដល់ រាជសំបថ ថា ការពារទឹកដីខេមរា ដល់ថ្ងៃ អវសានៗ

## គោលការណ៍ នយោបាយ នៅ ស្រុកខ្មែរ

គោលការណ៍ នយោបាយ របស់ អ្នកដឹកនាំ ហើយនឹង អ្នកនយោបាយ មាន មូលដ្ឋាន ត្រឹមតែ រស់មួយគែ ឬ វប្បធម៌ ធ្វើសិនៗ កង្វះ ចក្ខុវិស័យ នៃ អនាគត នេះឯង ដែលនាំ ឲ ជីវិតភាពនយោបាយ គ្មាន គុណសម្បត្តិ ទាំង បុគ្គលិកនយោបាយ និង សីលធម៌ៗ ប្រជាពលរដ្ឋ អធោ (peuple en bas) គ្មាន សេចក្តីទុកចិត្ត ទៅលើ អ្នកនយោបាយ ដោយ

[9] ពន្ទុមន្ត= អ្នកមានពូជពង្ស។

យល់ឃើញថា ជាទូទៅ សុទ្ធជា ជនពព្រួក, ឃ្លោកប្រាស់គ្មានអៀនខ្មាស់ យកនយោបាយធ្វើជា អាជិព ដើម្បី រស់ មាន យសស័ក្តិ ជា ឯកឧត្តម, ជំទាវ, សម្តេច ដែល ជា អធិបត្រ (certificat) សំរាប់ ប្រព្រឹត្តិ អំពើ ពុករលួយ ក្នុង គោលការណ៍ «អ្នកធំស៊ីតាមធំ, អ្នកតូច ស៊ីតាមតូច»ៗ គណបក្សកាន់អំណាច យក គោលការណ៍ នៃ អតិវឌ្ឍន៍របស់ រដ្ឋាភិបាល ធ្វើជា អតិសម័យ (réussite définitive) របស់ រដ្ឋាភិបាល មានជា ពស្តុតាង ដូចយ៉ាង ហេដ្ឋារចនាសម្ព័ន្ធ, ឧស្សាហកម្ម, មជ្ឈមពាណិជ្ជកម្ម ធំឆើតឆាយ, ធានាគារគ្រប់វិស័យ,ភោជនីយដ្ឋាន-សណ្ឋាគារទំនើបពាក់ផ្កាយ, មន្ទីរព្យាបាលរោគ សម័យ, មហាវិទ្យាល័យគ្រប់មុខវិជ្ជា, ហើយនឹង អ្វីៗ គ្រប់បែបយ៉ាង សំរាប់ បំរើ សេចក្តីត្រូវការ របស់ ទ្បេវទេសចរណ៍ គ្រប់ប្ញូរី មាន សោភ័នភាព បីដូច ឋាន សភាកាសៗ តែសំរិទ្ធដៃ (prospérité et victoire) នេះ ក៏ទុកដូច ជា គេមើលឃើញ កែវ មានទឹកពាក់កណ្តាល ឬ អត់ទឹកពាក់កណ្តាល ដូច្នេះ កង្វះទឹកពាក់កណ្តាល គឺប្រៀបដូចជា៖

- ហេដ្ឋារចនាសម្ព័ន្ធ ពព្រួក, ពេលភ្លៀងធ្លាក់ មាន ភក់ លុបប្បាត់ ខ្សែវិថី, មានស្ពានអាកាសតែគ្មាន សណ្តាប់ធ្នាប់ នៃ ចរាចរណ៍ បរបុកគ្នាស្លាប់ ពេញមួយនគរ ;

- ឧស្សាហកម្ម, មូលធន បរទេស, ជា ម៉ាស៊ីន ជញ្ជក់ កម្លាំង កម្មករ-កម្មការិនី ទទួលប្រាក់ឈ្នួលថោកបំផុត ;

- មជ្ឈមណ្ឌលពាណិជ្ជកម្ម សំរាប់ វណ្ណ: ឧកញ៉ា និង មន្ត្រីពុករលួយ, មានលុយកាក់ ពីរបរ ទុច្ចរិត, ចរលើលា រកទិញ សព្វវត្ថុ ប្រណិត ដឹកចូលមកលក់ ពីបរទេស ;

- ធានាគារ ពាណិជ្ជកម្ម សំរាប់ខ្ចីប្រាក់ មាន អត្រាការប្រាក់ខ្ពស់ លើសលប់ ដែល មិនអាចអោយ អ្នកសាមញ្ញ ទៅខ្ចីប្រាក់ប្បាន ដើម្បី ធ្វើ ជា មូលធន សំរាប់ ប្រកប របរជីវ: ព្រោះគ្មានធានាការ អតិវឌ្ឍន៍ សំរាប់ អ្នក ប្រកប របរការ ពាណិជ្ជកម្ម ;

- មន្ទីរព្យាបាលរោគ សម័យ តែ ឥតមាន គុណភាព ទាំង បុគ្គលិក ព្យាបាលរោគ និង ខ្វាត អនាម័យ, មិនតែប៉ុណ្ណោះ មានការរើសអើង រវាង អ្នកមាន នឹង អ្នកក្រ, ព្យាបាលជម្ងឺ តាមវិធីស្មាន ;

- មហាវិទ្យាល័យឯកជន ដុះដូចផ្សិត តែមិនស្របនឹង សេចក្តីត្រូវការ នៃ ផ្សារការងារ, ជា មជ្ឈមណ្ឌលអប់រំ មានគោលដៅ អត្ថាករ (but lucratif) ក្នុងប្រទេសមួយ ដែល ថាន: ជីវភាព មាន កំរិត ទាបបំផុតៗ ប្រព័ន្ធអប់រំ បែបនេះ ហុចផល អោយតែ គ្រួសារ មាន មធ្យោបាយ ហិរញ្ញវត្ថុ គ្រប់គ្រាន់ សំរាប់ បង់ ថ្លៃសាលា ដែល នាំអោយ កូនអ្នកក្រ គ្មាន វាសនា នឹងអាច ចេញពី ទលិទ្ទភាព តាមការចេះដឹង ឬានជាដាច់ខាតៗ ជា ពិសេសទៅ ទៀត ក្នុង ប្រព័ន្ធ អំពើ ពុករលួយ ជាទូទៅ នាំអោយ អ្នកមានលុយ និង អំណាច អាចទិញ សញ្ញាប័ត្រ អោយ កូនចៅខ្លួន ដែល ជា មូលហេតុ នៃការចុះ ថាន:សញ្ញាប័ត្រ ខ្មែរ ដោយ ប្រៀបធៀបនឹង សញ្ញាប័ត្រ នៃ ប្រទេស សមាជិក អាសេអាន(ASEAN) ;

- ក្នុងផ្នែក កសិកម្ម, នយោបាយ រដ្ឋាភិបាល គ្មាន គោលការណ៍អ្វី ក្រៅពី ជួលដី អោយក្រុមហ៊ុន បរទេស ភាគច្រើន មកកាប់ឈើលក់, ជីករក សិលាជាតិ, បំផ្លាញ សម្បត្តិធម្មជាតិ នាំអោយបាត់ សមតា នៃ ប្រព័ន្ធបរិស្ថាន (écosystème) នៅក្នុង ប្រទេស និង ក្នុងដំបន់ៗ កសិករ គ្មាន ការឧបត្ថម្ភ ពី ក្រសួង នាំអោយ ប្រជាជន រស់រំពឹង លើ ផលិតផល កសិកម្ម បរទេស គ្រប់បែបយ៉ាង ជាពិសេស ប្រទេសសៀម និង យៀកណាម ដើម្បី បរិភោគ រៀងរាល់ថ្ងៃៗ

- គោលការណ៍ នៃ នយោបាយ ទេសចរណ៍ សំរាប់ តែ ពួកឈ្មួញ រកចំណេញ គ្មាន ថែក ក់ម្រែតាមច្បាប់ ចូល ហិប ថវិកាជាតិ ហេតុតែ មាន អំពើ ពុករលួយ ពី លើ ដល់ ក្រោម នៅ ក្នុង ជួរ អ្នកដឹកនាំៗ

អភិវឌ្ឍន៍ ប្រទេស គឺជា ការរចំរើនលូតលាស់ នៃ សេដ្ឋកិច្ច និង សង្គមជាតិ ដូច អ្នក-វិទូសេដ្ឋកិច្ច (économistes) ធ្វើអនុសាស ដល់អ្នកដឹកនាំថា ដើម្បីអោយ សង្គម មាន សមតា លុះត្រា ភាពសម្បូណ៌ (richesse) នៃ សេដ្ឋកិច្ចជាតិ វាជា វេវចន: នឹង សុភមង្គល និង សុខុមាលភាព នៃ ប្រជាជន ដែលហៅថា ការបែងចែកភាគ នៃ សាច់ចំណេញ (bénéfice net) ត្រឹមត្រូវ រវាង សហគ្រាស-រដ្ឋ-គ្រួសេដ្ឋកិច្ច[10] (ménage), ពុំនោះទេ, សកម្មភាព នៃសេដ្ឋកិច្ចជាតិ គឺ គ្រាន់ តែ ជា សកម្មភាព នៃ ពាណិជ្ជកម្ម របស់ឈ្មួញទុច្ចរិត គិតតែ រកចំណេញ ដែលមាន អ្នកដឹកនាំ ពុករលួយ ជា អ្នកការពារ តែប៉ុណ្ណោះ។

រីឯ គោលការណ៍ របស់ អ្នកដឹកនាំ គណបក្សប្រឆាំង វិញ គាត់នាំគ្នា ចរច្រប[11] គ្មានច្រកចេញ ពី យុទ្ធសាស្ត្រយៀកណាម, ដើរទៅដើរមក កាត់តែ នៅពីក្រោយឆ្វាយ ពី គណបក្ស កាន់អំណាច ទុកណា មាន ចំនួន តំណាងរាស្ត្រច្រើន នៅក្នុង រដ្ឋសភា ក៏ នៅ តែញ៉ិញញ៉ុញ មិនដឹង ចង់ ធ្វើអ្វីមួយ ពិតប្រាកដៗ យក ឧបសាធន (accessoire) ធ្វើជាមូលធននយោបាយ ដូចយ៉ាង សុខចិត្ត ទទួលយក សម្លេង គណបក្សកាន់អំណាច ដើម្បីអង្គុយ លើកៅអី ប្រធាន នេះ ប្រធាន នោះ គ្មាន កិត្តិយស, ហើយ បើ គណបក្សកាន់អំណាច គេ (ចង់) ដេញចេញ គ្មាន អគារវ: តាមតែចិត្តគេ តែ ខ្លួន គ្មាន រាស្ត្រការពារ នាំគ្នាដើរចុះ ធ្វើមុខជូរ, តែថ្ងៃស្អែក គេ អោយឡាន មួយជិះ នាំគ្នា អរកខិបកខុប ភ្លេចគិត ទុក្ខនៅថ្ងៃស្អែក ហើយស្អែកមួយទៀត ហើយនាំគ្នា ស្រែក កកែកករ ថាជា មហាជោគជ័យ នៃវប្បធម៌សន្ទនា តាម របៀបបកស្រាយ (version) របស់ លោក កឹម សុខា ម្តង ព្រោះលោក សមរង្សី មាន ធុរ: នៅ បរទេសៗ របៀបបកស្រាយ នេះ គឺ សន្ទនា របៀប **ភាពគ** គឺថា មិនឆ្លើយ មិនឈ្លោះ ; នេះ ជា ការប្រឌិត ទ្រឹស្តីនយោបាយថ្មី នៅស្រុកខ្មែរ, តែ គេ

---

10 គ្រួសេដ្ឋកិច្ច : Ménage ; បុគ្គល ឬ គ្រួសារ រស់នៅក្នុងសកម្មភាពសេដ្ឋកិច្ច។
11 ចរច្រប= ដើរចុះឡើងសុសសព្វ។

អាចសួរថាតើ មិនចង់និយាយ ឬ និយាយមិនរួច (mutisme), តែ មួយណាក៏ដោយ គឺ វាគ្មាន ទំនងទាល់តែសោះ នៅក្នុង ជីវិតតាព នយោបាយ ព្រោះ នយោបាយ គឺ ជា សិន្ទួន (art de parole) ដែល ជននយោបាយ ម្នាក់ៗ ត្រូវតែមានៗ តែ លោក គឹម សុខា គាត់ច្បាស់ជាធ្វើ យុត្តិកម្ម ទ្រឹស្តីថ្មី របស់គាត់ ដោយយក តាសិត «ជោគជ័យ នៅទីបញ្ចប់ គឺបង្ហាញឧស្តុតាង នូវ ការប្រើ មធ្យោបាយ ត្រឹមត្រូវ» (la fin justifie les moyens), ដូច្នេះ ប្រើមធ្យោបាយ នៃ -តាពត- គឺ នឹងមាន ជោគជ័យ នៅពេល បោះឆ្នោត នៅឆ្នាំ ២០១៧-២០១៨ ; សាធុ! សាធុ!ៗ

គោលការណ៍នយោបាយ របស់ អ្នកដឹកនាំ គណបក្សប្រឆាំង គឺ ពួកគាត់ ឥតស្វែងរក វិសិដ្ឋតាព (excellence) នោះទេ ព្រោះ វា នាំខាន ដល់ សកម្មតាព របស់គាត់ គឺ រេតាមខ្យល់, ដូចយ៉ាង លោក សម រង្ស៊ី នៅពេលណា គាត់ មានទំនាក់ទំនងល្អ ជាមួយ លោក ហ៊ុន សែន គាត់ លែងមើលឃើញ ចំនួន ជនជាតិយួន រាប់លាននាក់ មករស់នៅខុសច្បាប់ នៅស្រុខ្មែរ តែ ពេលណា គាត់ មាន ជម្លោះ ជាមួយ មិត្ត ហ៊ុន សែន, គាត់ ដើរនិយាយថា នៅស្រុកខ្មែរ ច្បាស់ ជាមាន បំលាស់ប្តូរ ដូចនៅ ប្រទេស ភូមា ជា ពុំខាន ; តែគាត់ ភ្លេចគិត ថា អ្នកដឹកនាំ គណបក្សប្រឆាំង នៅ ភូមា គេ ស្វែងរក ជានិច្ច នូវ វិសិដ្ឋតាព ក្នុង គ្រប់ សកម្មតាពនយោបាយ របស់គេ ដែល នាំអោយ សហគម អន្តរជាតិ មានសេចក្តីទុកចិត្ត ហើយ គេធ្វើ សម្ពាធ ទៅលើ គណបក្សកាន់អំណាច តាម មធ្យោបាយទូតក្តី សេដ្ឋកិច្ចក្តី ដើម្បី អោយមាន ការផ្លាស់ប្តូរ តាម សន្តិវិធីៗ តើ លោក សម រង្ស៊ី និង គឹម សុខា មានបានសួរខ្លួនឯងទេ ថា សកម្មតាពនយោបាយ ឬាយឡុកឬាយឡ របស់ពួកគាត់ តើ អោយ នរណា គេ មាន សេចក្តីទុកចិត្តបានៗ មាន ប្រជាជន ? ពិតណាស់ ថា ប្រជាជនខ្មែរ ចង់ផ្លាស់ប្តូរ អ្នកដឹកនាំណាស់ តែបើ អ្នកដឹកនាំគណបក្សប្រឆាំង គ្មាន គោលការណ៍នយោបាយប្រឆាំង ពិតប្រាកដ ហើយ គាត់ គិត តែពីធ្វើ សហការ ជាមួយ អ្នកដឹកនាំ

ក្រោយ បោះឆ្នោត ដូចថ្មីនេះទៀត លោកស្រី ជូឡុងសូមេរា, ភរិយា លោក សម រង្ស៊ី, ត្រូវបាន គណបក្សកាន់អំណាច ស្នើរ ដាក់ បេក្ខភាព លោកស្រី ជា ប្រធាន គណកម្មការ ការអភិវឌ្ឍន៍ នៃសភា UPI ហើយ ត្រូវបាន សភា នេះ បោះឆ្នោតអោយ ; ពិតប្រាកដណាស់ថា តំណែងនេះ ជា មោទនភាព សំរាប់ជាតិ និង ស្ត្រីខ្មែរ, តែ សួរថា តើ ជា គោលការណ៍ត្រឹមត្រូវ ដែរឬទេ របស់ គណបក្សសង្គ្រោះជាតិ ដែល តែងតែ ទទួល កន្លែង កិត្តិយស ដោយសារ គណបក្សកាន់អំណាច ជានិច្ច ដែលនាំអោយមាន ភាពមិនច្បាស់លាស់ នៅក្នុងគោលជំហរ របស់ខ្លួន ? ដូច្នេះ តើ បំលាស់ប្តូរ នឹងអាច មានដូចនៅ ប្រទេសភូមា បានដែរឬទេ ដូចប្រសាសន៍ របស់ លោក សម រង្ស៊ី ? ជាពិសេស ទៅទៀត នៅស្រុកខ្មែរ មានអំណាច ឃៀកឃាម ជា អំណាចដឹកនាំ ដោយចំពោះលើ រដ្ឋាបាលខ្មែរ, ហេតុដូច្នេះហើយការត្រូវមាន វិសិដ្ឋភាព ក្នុង គោលការណ៍នយោបាយ របស់ អ្នកដឹកនាំ គណបក្សប្រឆាំង ជាការចាំបាច់ បូកនឹង សីលគន្ធ (bonne conduite) នៃបុគ្គលម្នាក់ៗ ទើបអាច នឹកមាន បំលាស់ប្តូរ ដូចនៅប្រទេស ភូមា បានៗ ការហ៊ានជំទាស់ (défi) នឹង អំណាច ឃៀកឃាម និង ផ្តាច់ការ នៅស្រុកខ្មែរ តម្រូវអោយ អ្នកដឹកនាំគណបក្សប្រឆាំង ពាក់ ឧត្តមគំនិត ជា អ្នកឈ្នះចិត្ត, ឈ្នះសីលធម៌, ឈ្នះនាយកធម៌, ឈ្នះពលិកម្ម និង ឈ្នះសេចក្តីក្លាហាន លើ គូប្រកួត របស់ខ្លួន, តែបើនៅតែបន្ត អនុវត្ត វប្បធម៌សន្ទនា ជា អ្នកចាញ់ទាំង កម្លាំងនិងចិត្ត គឺ ពិតជា ស្ថិតនៅក្នុង សណ្ឋាន និង គោលការណ៍ ជា អ្នកកំសាកតែប៉ុណ្ណោះៗ ហើយ សេចក្តីក្លាហាន នោះទៀត មិនមែនមាន ន័យថា អោយ អ្នកដឹកនាំ គណបបក្សប្រឆាំង កាន់អាវុធតស៊ូ ឬ ដុតខ្លួននោះឡើយ គឺ គ្រាន់តែអោយ ពួកគាត់ ធ្វើអំពើប្រឆាំង អោយ ដូច គាត់នាំគ្នានិយាយ និង សន្យា នៅចំពោះមុខ ប្រជាពលរដ្ឋ និង មាន សេចក្តីថ្លៃថ្នូរ ដូច លោក គឹម សុខា គាត់ ថ្លែងថា មិនលក់កិត្តិយស ដាច់ខាតៗ មួយជំហ៊ានម្តងៗ, វប្បធម៌សន្ទនា, មិនឆ្លើយមិនឈ្លោះ មិនមែន ជា គោលការណ៍នយោបាយ ជាសកម្ម, ផ្ទុយទៅវិញ វា ជា

សណ្ឋាននយោបាយ និច្ចល សំរាប់តែនាំគ្នាឈរ កុំអោយ រអិល នៅ ក្នុង ប្រព័ន្ធយៀកណាម តែប៉ុណ្ណោះ ព្រោះ ស្ថិរភាព នេះ វា ជា ប្រយោជន៏ឯកជន របស់ ពួកគាត់ៗ

## សេចក្តីសន្និដ្ឋាន

យើងឃើញថា គណបក្សកាន់អំណាចក្តី គណបក្សប្រឆាំងក្តី រស់នៅក្នុង ប្រព័ន្ធតែមួយ មានប្រយោជន៏រួម, ការពារ បុព្វសិទ្ធិ របស់ខ្លួន រៀងៗខ្លួនៗ គណបក្សប្រឆាំង ពិតជាចង់ដូរអ្នកដឹកនាំ តែមិនច្បាស់ ជា ចង់ដូរ របៀបដឹកនាំ នោះឡើយ ហេតុនេះឯង បាន ជា គេអាចធ្វើសហការ ជាមួយគ្នាបាន នៅក្នុង ជម្លោះសិប្បនិម្មិត ដើម្បី នាំគ្នាការពារ ពិធីប្រជាធិបតេយ្យ (démocrature) ព្រោះវា ជា មធ្យោបាយ នៃ អត្ថភាព រៀងៗខ្លួនៗ អ្នកប្រឆាំង ដើរតួជាអ្នកចាញ់ តែ បានទទួលកម្រៃ គ្រប់បែបយ៉ាង, អ្នកកាន់អំណាច ដើរតួជាអ្នកឈ្នះជានិច្ច តែត្រូវតែ ការពារប្រយោជន៏ យៀកណាម នៅស្រុកខ្មែរ ទើប អាច រស់ ជា អ្នកផ្តាច់ការបានៗ នេះហើយ ជា សណ្ឋាននយោបាយ និង គោលការណ៏នយោបាយ របស់ អ្នកដឹកនាំគណបក្សនៅស្រុកខ្មែរៗ សួរថា តើ សណ្ឋាននយោបាយ និង គោលការណ៏នយោបាយ របស់ប្រជាពលរដ្ឋខ្មែរ វិញ វា មាន សភាព បែបណាដែរ ? បើ និយាយថា ជា ការចាញ់ប្រោកអ្នកនយោបាយ ដូចជា មិនទំនងសោះ ព្រោះ ការចាញ់ប្រោក វាអាចមានតែមួយដង តែដល់មានរហូត តើ ការចាញ់ប្រោក នេះ អាចទុកជាអ្វីទៅ ?